**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០ សរណ

# សេចក្ដីអំពាវនាវរបស់រាជរដ្ឋាភិបាល

នៅក្នុងឆ្នាំ២០១៣នេះ ប្រទេសកម្ពុជាបានទទួលរងគ្រោះដោយសារគ្រោះធម្មជាតិ និងទឹកជំនន់ធ្ងន់ធ្ងរ ដែលបណ្ដាលឲ្យមានការប៉ះពាល់ដល់ផលដំណាំកសិកម្ម របស់ប្រជាកសិករ អាជីវកម្មខ្នាតតូច និងមធ្យម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងប្រព័ន្ធធារាសាស្ត្រ នៅតាមបណ្ដាខេត្ត-ក្រុងមួយចំនួន ជាពិសេសមានការប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋដែលជាអតិថិជនរបស់គ្រឹះស្ថានធនាគារ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ។

ឆ្លៀតក្នុងឱកាសនេះ ដើម្បីជួយសម្រាលដល់ប្រជាពលរដ្ឋដែលកំពុងទទួលរងគ្រោះដោយសារគ្រោះធម្មជាតិ ជាពិសេសគ្រោះទឹកជំនន់នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាសូមអំពាវនាវដល់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដូចខាងក្រោម៖

១.ចំពោះប្រជាពលរដ្ឋដែលជាអតិថិជនកំពុងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងគ្មានលទ្ធភាពសងបំណុលត្រលប់វិញទាន់ពេលវេលា សូមផ្ដល់ការអនុគ្រោះជូនប្រជាពលរដ្ឋទាំងនោះ ដោយមិនបង្ខំឲ្យពួកគាត់ធ្វើការលក់ផ្ទះ ឬដីធ្លី ដែលជាទ្រព្យបញ្ចាំធានាឥណទានយកមកសងបំណុល ឬរឹបអូសទ្រព្យបញ្ចាំនោះ ។

២.ចំពោះឥណទានដល់កាលកំណត់សង សូមពិនិត្យលទ្ធភាពពន្យារពេលសងឥណទានជាមួយនឹងការអនុគ្រោះមិនផាកពិន័យ មិនយកការប្រាក់ ឬ យកការប្រាក់ទាប តាមដែលអាចធ្វើបាន។

៣.សូមពិនិត្យលទ្ធភាពផ្ដល់ឥណទានបន្ថែម ជាមួយនឹងអត្រាការប្រាក់ទាប ដើម្បីផ្ដល់ឱកាសឲ្យប្រជាពលរដ្ឋជាអ្នករងគ្រោះអាច ស្ដារជីវភាពរស់នៅឡើងវិញ តាមរយៈការធ្វើស្រូវប្រាំង ឬស្រូវប្រដេញទឹក ក៏ដូចជាការដាំដុះដំណាំ និងអាជីវកម្មផ្សេងៗ ទៀត។

រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ ក្នុងនាមជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដើម្បីត្រួតពិនិត្យ និងតាមដានការអនុវត្តសេចក្ដីអំពាវនាវ ខាងលើ។

រាជរដ្ឋាភិបាលសង្ឃឹម និងជឿជាក់ថា គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូ-ហិរញ្ញវត្ថុ និងដៃគូពាក់ព័ន្ធទាំងអស់ នឹងចូលរួមសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួយសម្រាលដល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋ ដែលកំពុងរងគ្រោះដោយសារគ្រោះធម្មជាតិ ជាពិសេសទឹកជំនន់នៅក្នុងឆ្នាំនេះដូចកាលពីឆ្នាំ២០១១កន្លងទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**